# សុន្ទរកថា លោកជំទាវ នាង ចន្ធំថាណា ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
# ក្នុងឱកាសបើកសម្ពោធ WING ជាផ្លូវការ
# ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩

សូមគោរពលោក Mike Smith នាយកប្រតិបត្តិក្រុមហ៊ុន ANZ Global

ឯកឧត្តម លោកជំទាវ លោក លោកស្រី និងភ្ញៀវកិត្តិយស ជាទីរាប់អាន។

ថ្ងៃនេះជាទិវាដ៏មហានក្ខត្តឫក្ស ដែលនាងខ្ញុំបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា ដើម្បីចូលរួមក្នុងពិធីបើកសម្ពោធការិយាល័យ WING ។

ជាបឋម នាងខ្ញុំសូមថ្លែងអំណរគុណចំពោះលោក Mike Smith ចំពោះអំណោយរបស់លោក និងសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះទស្សនកិច្ចលើកដំបូងរបស់លោកមកកាន់ព្រះរាជាណាចក្រកម្ពុជា ។

ប្រទេសកម្ពុជាមានមោទនភាពណាស់ដោយមានស្ថាបន័លំដាប់ខ្ពស់ ANZ Royal បន្តការវិនិយោគនៅក្នុងទីផ្សាររបស់យើង ។

ANZ បានដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងការអភិវឌ្ឍសេវាហិរញ្ញវត្ថុរបស់កម្ពុជា ចាប់តាំងពីការបើកដំណើការធនាគារ ANZ Royal នៅឆ្នាំ២00៥ មក។

ការបង្កើតសេវាធនាគារថ្មី ដូចជា Blue Spot និង ATM របស់ធនាគារ ANZ ជាសក្ខីភាពបង្ហាញថាប្រទេសកម្ពុជាបានឈានទៅប្រើប្រាស់សេវាធនាគារ ដែលមានកំរិតខ្ពស់ដូចនៅប្រទេសអូស្រ្តាលី និងប្រទេសញ៉ូសេឡិនដែរ។

ការផ្តួចផ្តើមរបស់ Wing ក្នុងការបង្កើតសេវា M-Payment នឹងជួយប្រជាជនដែលមានចំណូលទាបជាពិសេសប្រជាជនដែលចាកចេញពីស្រុកកំណើតដើម្បីមកធ្វើការនៅទីប្រជុំជន អាចផ្ទេរប្រាក់ចំណូលដែលរកបានទៅស្រុកកំណើតរបស់គេ និងអាចដក និងដាក់ប្រាក់ ដែលមានកម្រៃសេវាទាបតាមរយៈភ្នាក់ងារ Wing ។

ការទទួលបានជោគជយ័នៃគម្រោងសាកល្បងរបស់ Wing នាពេលថ្មីៗនេះ បានបង្ហាញថា Wing ដែលបានការជួយឧបត្ថម្ភពីភ្នាក់ងារ ANZ Royal នឹងផ្តល់សេវា M-payment ដល់អតិថិជនតែជាប្រាក់រៀលប៉ុណ្ណោះ។ ធនាគារជាតិនៃកម្ពុជាមានសេចក្តីរីករាយ និងពេញចិត្តយ៉ាងខ្លាំងចំពោះគម្រោងនេះ ដោយសារគម្រោងនេះ

នឹងជំរុញឱ្យមានការប្រើប្រាស់ប្រាក់រៀល និងអាចនាំពង្រីកនូវហិរញ្ញប្បទានសម្បូរបែបទៅដល់វិស័យមិនមែនធនាគារ ។

យើងជឿជាក់ថា Wing នឹងផ្តល់សេវាដែលចាំបាច់ជាច្រើនដល់អតិជនដែលរស់នៅតំបន់ដាច់ស្រយាលដែលបច្ចុប្បន្នមិនទាន់មាននរណាម្នាក់ទទួលបានសេវាធនាគារ ឬសេវាទូទាត់នៅឡើយទេ ។ យើងតែងតែត្រៀមខ្លួនជានិច្ចក្នុងការសហការជាមួយស្ថាប័នដែលមានឆន្ទៈក្នុងការអភិវឌ្ឍនូវផលិតផលថ្មីៗ ដូចជា ANZ ជាដើម ។

ការប្រើប្រាស់សេវា M-Payment នឹងនាំមកនូវនិរន្តរភាពនៃអត្ថប្រយោជន៍ចំពោះសង្គម និងសេដ្ឋកិច្ចកម្ពុជា និងជួយជម្រុញដល់យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល រួមមាន កំណើនសេដ្ឋកិច្ច ផ្តល់ការងារធ្វើ សមភាព និងប្រសិទ្ធិភាព ។

ក- **កំណើន** : WING នឹងផ្តល់ឱ្យប្រជាជនកម្ពុជាអាចមានលទ្ធភាពប្រើប្រាស់សេវាហិរញ្ញវត្ថុកាន់តែច្រើនថែមទៀត ជាងសេវាដែលមាននាពេលបច្ចុប្បន្ន ។ ទន្ទឹមនេះ WING ក៏ផ្តល់ផងដែរដល់ប្រជាជនកម្ពុជាអាចរក្សាប្រាក់របស់គេប្រកបដោយសុវត្ថិភាព ដើម្បីទិញទំនិញធំៗនៅពេលមានតម្រូវការ ដូចជា ជីរកសិកម្ម គ្រាប់ពូជ អំណោយ និងមធ្យោបាយធ្វើដំណើរ ។

ខ- **ផ្តល់ការងារធ្វើ** : ថ្មីៗនេះ WING មានបុគ្គលិកជាជនជាតិកម្ពុជាចំនួន៨០នាក់ ហើយនឹងអាចផ្តល់ចំណូលដល់ភ្នាក់ងារលក់របស់ Wing និង Wing cash Express (អ្នកទទួលការដាក់ប្រាក់ និងដកប្រាក់) ចំនួនរាប់រយនាក់ ។

គ- **សមភាព** : WING នឹងផ្តល់សេវាដូចគ្នាដល់អតិថិជនទាំងអស់ដោយមិនគិតពីឋានៈ ឬទ្រព្យសម្បត្តិឡើយ ។ ពោលគឺអតិថិជនទាំងអស់មានភាពស្មើគ្នាក្នុងការទទួល និងប្រើប្រាស់សេវាអតិថិជនរបស់ WING ។

ឃ- **ប្រសិទ្ធភាព** : WING ផ្តល់ឱ្យកំលាំងពលកម្មអណ្តែតរបស់យើងនូវលទ្ធភាពអាចរក្សាបានទំនាក់ទំនងហិរញ្ញវត្ថុជាមួយក្រុមគ្រួសាររបស់ពួកគេបានឆាប់រហ័សជាងមុន ហើយសាច់ប្រាក់អាចទៅដល់ដៃក្រុមគ្រួសាររបស់គេបានភ្លាមៗ ដើម្បីធានាថាគ្រួសារគេអាចមានអាហារ សំលៀកបំពាក់ និងលំនៅដ្ឋានដោយខ្លួនគេ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់**

ធនាគារជាតិនៃកម្ពុជាមានជំនឿយ៉ាងមុតមាំថា WING នឹងរួមចំណែកជាវិជ្ជមានចំពោះវិស័យហិរញ្ញវត្ថុនៅកម្ពុជា ។ យើងផ្តល់ការលើកទឹកចិត្តចំពោះ WING ក្នុងការសហការជាមួយធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀតដើម្បីពង្រីកសេវាហិរញ្ញវត្ថុដល់ជនបទ ។

ធនាគារជាតិនៃកម្ពុជា ទទួលស្គាល់នូវសារៈសំខាន់នៃទីផ្សារមិនមែនធនាគារនាបច្ចុប្បន្នដែល WING នឹងផ្តល់សេវានេះ ហើយនេះគឺជាការងាររបស់យើងក្នុងការជួយការពារ និងធានាថាសេវានេះមានភាពត្រឹមត្រូវតម្លៃសមរម្យ និងមានសមភាព ។

យើងនឹងបន្តធ្វើការជាមួយ WING និងស្ថាប័នដែលមានកិត្តិសព្ទ ដូចជា IFC ដើម្បីបង្កើនចំណេះដឹងថែមទៀតលើផ្នែកមិនមែនធនាគារនៅក្នុងទីផ្សារកំពុងអភិវឌ្ឍដទៃទៀត ។

យើងនឹងបន្តតាមដាន គ្រប់គ្រង និងសហការជាមួយ WING ជាទៀងទាត់ ដើម្បីតាមដានភាពជោគជ័យនេះបន្តទៀត និងការផ្តល់តម្លៃដល់កម្ពុជា ។

ធនាគារជាតិនៃកម្ពុជាសូមថ្លែងអំណរគុណចំពោះ WING និងជាពិសេស ANZ ចំពោះកិច្ចសហការយ៉ាងជិតស្និទ្ធ និងគោរពតាមធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើតបាននូវបទដ្ឋានច្បាប់សាកល្បងមួយដ៏រឹងមាំ ។

ធនាគារជាតិនឹងគាំទ្រចំពោះការខិតខំប្រឹងប្រែងរបស់ WING ក្នុងការបង្កើតសកម្មភាពសេវានេះនៅកម្ពុជា។ យើងត្រៀមលក្ខណៈធ្វើការជាមួយលោក Mike Smith និងក្រុមការងាររបស់លោកបន្ថែមទៀតនៅពេលអនាគត ។

### ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់

តាងនាមឱ្យធនាគារជាតិនៃកម្ពុជា ខ្ញុំសូមសម្តែងការអបអរសាទរ និងប្រសិទ្ធពរចំពោះ WING ដែលបានផ្តួចផ្តើមបង្កើតសេវានេះនៅកម្ពុជា ។ សេវានេះមានសារៈសំខាន់ណាស់ ដោយមិនគ្រាន់តែអាចឱ្យប្រជាជនដែលមានចំណូលទាបអាចប្រើប្រាស់សេវាធនាគារប៉ុណ្ណោះទេ ថែមទាំងអាចពង្រីកសកម្មភាពធនាគារនៅក្នុងតំបន់ ជនបទថែមទៀត ពោលគឺសេវានេះបានរួមចំណែកក្នុងការធ្វើឱ្យកំណើនសេដ្ឋកិច្ចកម្ពុជាដំណើរការដោយរលូន ។

ជាទីបញ្ចប់ ខ្ញុំសូមប្រគល់ជូននូវលិខិតអនុញ្ញាតបើកដំណើការ WING នៅក្នុងទីផ្សារកម្ពុជា និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការបន្តវិនិយោគ និងអភិវឌ្ឍនៅកម្ពុជា ។

**សូមអរគុណ**